# អារម្ភកថា និង ការថ្លែងអំណរគុណ

"ខ្ញុំមិនដែលនិយាយជាមួយម្តាយរបស់ខ្ញុំអំពីជីវិតរបស់គាត់នៅក្នុងរបបខ្មែរក្រហមទេ ហើយនេះជាលើកដំបូងនៅក្នុងជីវិតរបស់ខ្ញុំ នៅពេលដែលខ្ញុំចុះធ្វើការស្ទាបស្ទង់មតិអំពីសាលាជំរះក្តីកាត់ទោសខ្មែរក្រហម ទើបខ្ញុំ បានដឹងថា ក្រុមគ្រួសាររបស់ខ្ញុំ បានបាត់បង់សមាជិកជាង ១០នាក់" នេះជាសម្តីរបស់បុគ្គលិកម្នាក់នៃ "វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ" (KID) ស្ថិតក្នុងវ័យជាងម្ភៃឆ្នាំ ក្នុងនាមយុវជនជំនាន់ក្រោយជាច្រើននាក់ទៀត ដែលមិនបានដឹងអំពីអំពើឃោរឃៅព្រៃផ្សៃ និងទុក្ខវេទនានៅក្នុងសម័យនោះ ។ បុគ្គលិកម្នាក់ ទៀតបានរកឃើញថា ឪពុកម្តាយរបស់នាងត្រូវបានកម្មាភិបាលខ្មែរក្រហម បង្ខំឱ្យរៀបការចំណែក អ្នកសម្ភាសន៍ទីបី មានការភ្ញាក់ផ្អើលដោយបានដឹងថា "មិនមែនខ្មែរក្រហមទាំងអស់សុទ្ធតែអាក្រក់ទេ តែក៏ មានមនុស្សល្អខ្លះដែរ" ។

យើងទាំងអស់គ្នា ជាមន្ត្រីកម្មវិធីនៃវិទ្យាស្ថាន ផ្នែកគំរោង "គោលការណ៍ជំនុំជំរះដោយយុត្តិធម៌ពាក់ព័ន្ធនឹងសាលាជំរះក្តីកាត់ទោសខ្មែរក្រហម នាពេលអនាគតខាងមុខនេះ" បានប្រឈមមុខជាមួយប្រវត្តិសាស្ត្ររបស់យើង ដោយការសាកសួរផ្ទាល់ពីអ្នកដែលនៅរស់រានមានជីវិតពីរបបនោះ និងស្តាប់រឿងរ៉ាវ អារម្មណ៍ តំរូវការ និងក្តីសង្ឃឹមរបស់ពួកគាត់ ដើម្បីកុំឱ្យ កម្លាំង សតិបញ្ញា ការឈឺចាប់ និងទុក្ខវេទនារបស់ពួកគាត់សាបសូន្យទៅ ។

យោងតាមមាត្រា ១៥ នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ ១៩៩១ បានចែងថា "ប្រទេសកម្ពុជា ត្រូវចាត់វិធានការដែលមានប្រសិទ្ធិភាព ដើម្បីធានាថា គោលនយោបាយ និងការអនុវត្តន៍នៅក្នុងអតីតកាល មិនត្រូវអនុញ្ញាតឱ្យវិលត្រឡប់មកវិញឡើយ" ។

ដោយមិនបំភ្លេចនូវបេសកកម្មដែលត្រូវបំពេញឱ្យអស់ពីសមត្ថភាព និងអវត្តមាននៃវេទិការពិភាក្សាសាធារណៈដែលមានទ្រង់ទ្រាយធំ ស្តីអំពី អំពើព្រៃផ្សៃពីអតីតកាល ថាតើគួរតែទទួលខុសត្រូវតាមរបៀបណា? តាមរយៈការស្ទាបស្ទង់មតិនេះ វិទ្យាស្ថានមានបំណងផ្តល់ឱ្យប្រជាពលរដ្ឋបញ្ចេញនូវតំរូវការ និងសេចក្តីប្រាថ្នារបស់ខ្លួន ។ ប៉ុន្តែជាអកុសល ការសំរេចដ៏មានសារៈសំខាន់ជាមូលដ្ឋាន ស្តីពី តុលាការកាត់ទោសខ្មែរក្រហមត្រូវបានប្រគល់ឱ្យតែអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ប៉ុណ្ណោះ ។ ភាគីទាំងពីរនេះមិនដែលពិចារណាដល់ការស្វែងរកមតិសាធារណៈជន ដើម្បីឱ្យពួកគេមានអារម្មណ៍ធូរស្រាលពីសុបិន្តអាក្រក់របស់ពួកគេឡើយ ។ ទោះជាយ៉ាងណាក៏ដោយ យើងបានព្យាយាមប្រគល់អំណាចដល់ប្រជាពលរដ្ឋខ្មែរ ដើម្បីចូលរួមចែករំលែកព័ត៌មានអំពីផលប្រយោជន៍សាធារណៈដ៏ធំធេង នឹងបង្ហាញពីទស្សនៈក៏ដូចជាមធ្យោបាយដើម្បីដោះស្រាយពីបញ្ហាអតីតកាលរបស់ពួកគេ ។

ប្រជាពលរដ្ឋភាគច្រើនដែលយើងបានសម្ភាសន៍មានការត្រេកអរចំពោះកិច្ចប្រឹងប្រែង ដើម្បីបង្កើតការជំនុំជំរះមួយ ពីព្រោះថា របបខ្មែរក្រហមដ៏សាហាវឃោរឃៅបានទទួលបរាជ័យក្នុងសង្គ្រាមហើយ តែមិនទាន់មានការដោះស្រាយតាមផ្លូវច្បាប់នៅឡើយ ។ ពេលវេលាកំពុងតែ ខិតជិតដល់ទីបញ្ចប់ហើយ សំរាប់ការនាំ

អ្នកដែលទទួលខុសត្រូវខ្ពស់បំផុតទៅជំនុំជំរះ ។ ប្រសិនបើការជំនុំជំរះនេះមិនកើតឡើងទេនោះ ប្រទេសកម្ពុជានឹងមិនអាចក្លាយជានីតិរដ្ឋ និងមិនអាចអភិវឌ្ឍន៍ទៅជាប្រទេសមួយដែលមានសន្តិភាព និងភាពចំរើន-រុងរឿងបានឡើយ ។ សេចក្តីប្រាថ្នារបស់យើង គឺចង់ឱ្យការស្ទាបស្ទង់មតិនេះ ជាការចូលរួមចំណែកដល់កិច្ចប្រឹងប្រែងនេះ ក្រោយពីប្រជាពលរដ្ឋខ្មែរបានរង់ចាំយុត្តិធម៌អស់រយៈពេល ២៥ឆ្នាំ មកហើយ ។

យើងសូមថ្លែងអំណរគុណដល់អ្នកផ្តល់សម្ភាសន៍ទាំងអស់ ចំពោះការបើកចំហ កិច្ចសហការបែបស្ថាបនា និងការអត់ធ្មត់របស់ពួកគេ ។ យើងក៏សូមសម្តែងនូវការដឹងគុណដ៏ជ្រាលជ្រៅផងដែរ ដល់អ្នកស្ម័គ្រចិត្តធ្វើសម្ភាសន៍ទាំងអស់របស់យើង ដែលបានជួយធ្វើឱ្យការស្ទង់មតិនេះទទួលជោគជ័យ ។ លើសពីនេះទៀត យើងសូមអរគុណដល់ លោក **ម៉ារ៉ឌី ចំរើនសំភ្លី** ជាវិស្វករផ្នែកឧស្សាហកម្ម និងកម្មសិក្សាការីរបស់វិទ្យាស្ថាន កញ្ញា **ជេននី គ្រោនបក ឡាសេន** ដែលបានជួយជ្រោមជ្រែងក្នុងការបង្កើត និងការប្រើប្រាស់ "កម្មវិធីស្ថិតិសំរាប់ការស្ទង់មតិសង្គម" (**SPSS**) ។

វិទ្យាស្ថានក៏សូមថ្លែងអំណរគុណផងដែរ ដល់ស្ថានទូតអាល្លឺម៉ង់ និងសេវាអភិវឌ្ឍន៍របស់ព្រះវិហារ (**EED –** ប្រទេសអាល្លឺម៉ង់) ដែលបានផ្តល់ថវិកាដោយចិត្តសប្បុរសដល់គំរោងនេះ ។

រាជធានីភ្នំពេញ ខែតុលា ឆ្នាំ ២០០៤

| | | | |
|---|---|---|---|
| **ពេញ** | **ប៊ុនឆេង** | **ជូ** | **ចន្ទ្រា** |
| **ឈូក** | **គឹមម៉ៅ** | **ម៉ែន** | **ច័ន្ទសុកុល** |
| **ឃួត** | **សុធារី** | **នាង** | **សុវត្ថារ៉ា** |
| **បេម** | **អាន់ត្រេអា** | | |